ឈ្មោះទីក្រុង

# សេចក្តីជូនដំណឹងស្តីពីវ៉ាក់សាំងការពារមេរោគកូរ៉ូណា




## ដំណើរការចាក់វ៉ាក់សាំង

ចាក់វ៉ាក់សាំង
**ឥតគិតថ្លៃ**
(ឧបត្ថម្ភទាំងស្រុងដោយរដ្ឋាភិបាល)

## 1 បញ្ជាក់ពេលវេលាដែលអ្នកអាចមកចាក់វ៉ាក់សាំងបាន

វ៉ាក់សាំងមេរោគកូរ៉ូណា នឹងផ្តល់ជូនតាមលំដាប់ទៅឱ្យ **បុគ្គលិកថែទាំសុខភាព មនុស្សចាស់ និងអ្នកដែលមានជំងឺប្រចាំកាយ។** សូមបញ្ជាក់អំពីលំដាប់លំដោយទទួលវ៉ាក់សាំងរបស់អ្នក ហើយរង់ចាំវេនរបស់អ្នក។

*សូមរង់ចាំសេចក្តីប្រកាសពីរដ្ឋាភិបាល។ អ្នកអាចចូលទៅមើលក្នុងវែបសាយត៍របស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព ឬទៅកន្លែងពិគ្រោះយោបល់នៅក្នុងទីក្រុងរបស់អ្នក។
*សូមមើលផ្នែកខាងក្រោយនៃឯកសារនេះ អំពីវិសាលភាពមនុស្សចាស់ និងអ្នកដែលមានជំងឺប្រចាំកាយ។
*ទោះបីជាអ្នកអាចនឹងត្រូវរង់ចាំបន្តិចក៏ដោយ ក៏យើងនឹងធានាឱ្យបានថាអ្នកដែលចង់ចាក់វ៉ាក់សាំងនឹងអាចមានឱកាសទទួលបានវ៉ាក់សាំងនេះ ដូច្នេះសូមមានភាពអត់ធ្មត់បន្តិច។

## 2 ស្វែងរកមន្ទីរពេទ្យ ឬកន្លែងចាក់វ៉ាក់សាំង



ស្វែងរកមន្ទីរពេទ្យ ឬកន្លែងចាក់វ៉ាក់សាំងដែលអ្នកអាចទៅចាក់វ៉ាក់សាំងបានតាមរយៈ PR នៅក្នុងរាជធានី ទីក្រុងរបស់អ្នក ឬនៅលើប្រព័ន្ធអ៊ីនធឺណិត។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វែបសាយត៍ព័ត៌មានទូទៅស្តីពី **ការណែនាំអំពីវ៉ាក់សាំងការពារមេរោគកូរ៉ូណា** នៅខាងស្តាំនេះ។

វែបសាយត៍ស្តីពីការណែនាំអំពីវ៉ាក់សាំងការពារមេរោគកូរ៉ូណា៖ https://v-sys.mhlw.go.jp

*អ្នកអាចទាក់ទងទៅកាន់សាលាក្រុងរបស់អ្នកបាន ប្រសិនបើអ្នកមិនអាចស្វែងរកមន្ទីរពេទ្យ ឬកន្លែងចាក់វ៉ាក់សាំងបានទេនោះ។
*វ៉ាក់សាំងគួរតែផ្តល់ជូននៅក្នុងរាជធានី ទីក្រុង ឬភូមិដែលអ្នកចុះបញ្ជីលំនៅដ្ឋានរបស់អ្នក (ទីតាំងលំនៅដ្ឋាន) លើកលែងតែអ្នកត្រូវសម្រាកក្នុងមន្ទីរពេទ្យ ឬត្រូវចូលសម្រាកនៅក្នុងមូលដ្ឋានសុខាភិបាល។
សូមមើលផ្នែកខាងក្រោយសម្រាប់ព័ត៌មានអំពីការចាក់វ៉ាក់សាំងនៅតំបន់ផ្សេងពីអាសយដ្ឋានដែលបានចុះបញ្ជី។
*អ្នកមិនអាចធ្វើការណាត់ជួបដោយផ្ទាល់តាមរយៈវែបសាយត៍ណែនាំអំពីវ៉ាក់សាំងការពារមេរោគកូរ៉ូណាបាននោះទេ។

កូដបន្ទាប់បន្សំសម្រាប់ការណែនាំអំពីវ៉ាក់សាំងការពារមេរោគកូរ៉ូណា

## 3 ធ្វើការណាត់ជួប និងការចាក់វ៉ាក់សាំង



សូមទាក់ទងទៅកាន់មន្ទីរពេទ្យ ឬសាលាក្រុងដែលអ្នកចង់ចាក់វ៉ាក់សាំង។

| | |
|---|---|
| មន្ទីរពេទ្យនៅក្នុងតំបន់របស់អ្នក | ធ្វើការណាត់ជួបដោយផ្ទាល់ជាមួយនឹងមន្ទីរពេទ្យ (តាមរយៈទូរសព្ទ អ៊ីនធឺណិតជាដើម) |
| កន្លែងចាក់វ៉ាក់សាំងនៅក្នុងទីក្រុង | លេខទំនាក់ទំនង |

**ឯកសារចាំបាច់**

- **បង្កាន់ដៃ (មានបង្ហាញនៅក្នុងសេចក្តីជូនដំណឹងនេះ)**
- **ឯកសារបញ្ជាក់អត្តសញ្ញាណ (ប័ណ្ណបើកបរ ប័ណ្ណធានារ៉ាប់រង ជាដើម)**



*សូមវាស់កម្តៅរាងកាយរបស់អ្នកនៅផ្ទះ មុនពេលមកចាក់វ៉ាក់សាំង ហើយសូមកុំចាក់វ៉ាក់សាំង និងត្រូវទាក់ទងទៅកាន់ការិយាល័យសាលាក្រុង ឬមន្ទីរពេទ្យដែលអ្នកបានណាត់ដើម្បីចាក់វ៉ាក់សាំងនោះភ្លាម ប្រសិនបើអ្នកមានជំងឺគ្រុនក្តៅ ឬមានអារម្មណ៍មិនស្រួលខ្លួន។
*សូមស្លៀកសម្លៀកបំពាក់ដែលងាយស្រួលបើកស្មា។
*ដើម្បីទទួលបានប្រសិទ្ធភាពវ៉ាក់សាំងនេះពេញលេញ អ្នកត្រូវតែចាក់វ៉ាក់សាំងប្រភេទតែមួយឱ្យបាន 2 ដូសនៅក្នុងចន្លោះពេលកំណត់ណាមួយ។ នៅពេលដែលអ្នកទទួលបានវ៉ាក់សាំងដូសទីមួយ សូមពិនិត្យមើលពេលវេលាដែលអ្នកត្រូវទៅចាក់ដូសបន្ទាប់។
*បង្កាន់ដៃដែលមានបង្ហាញគឺសម្រាប់លិខិតបញ្ជាក់ការចាក់ថ្នាំបង្ការ ឬលិខិតបញ្ជាក់ការចាក់វ៉ាក់សាំង។ សូមយកឯកសារនេះមកជាមួយអ្នកឱ្យបានគ្រប់ពេល ហើយសូមកុំដកឯកសារនេះចេញពីគ្នាឱ្យសោះ។

## ◎ ចាប់ផ្តើមចាក់វ៉ាក់សាំងសម្រាប់មនុស្សចាស់

នៅពេលដែលវ៉ាក់សាំងត្រូវបានរៀបចំផ្តល់ជូនអ្នកដែលមានអាយុ 65 ឆ្នាំក្នុងឆ្នាំហិរញ្ញវត្ថុ 2021 (អ្នកដែលកើតនៅថ្ងៃ ឬមុនថ្ងៃទី01 ខែមេសា ឆ្នាំ1957) រយៈពេលនេះអាចនឹងត្រូវបែងចែកបន្ថែមទៀត។

## ◎ តើអ្នកដែលមានជំងឺប្រចាំកាយមានស្ថានភាពបែបណា?

វ៉ាក់សាំងសម្រាប់អ្នកដែលមានជំងឺប្រចាំកាយ គឺនឹងត្រូវផ្តល់ជូន បន្ទាប់ពីការចាក់ឱ្យមនុស្សចាស់ទូទៅរួច។ អ្នកដែលមានជំងឺប្រចាំកាយ គឺត្រូវបានកំណត់អត្តសញ្ញាណថាជាអ្នកដែលមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម (គិតត្រឹមថ្ងៃទី01 ខែកុម្ភៈ ឆ្នាំ2021 ហើយអាចនឹងមានការផ្លាស់ប្តូរ)

1. អ្នកដែលមានជំងឺ និងស្ថានភាពដូចខាងក្រោមដែលទទួលការថែទាំជំងឺក្រៅ ឬជំងឺក្នុង
   1. ជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ
   2. ជំងឺបេះដូងរ៉ាំរ៉ៃ (រួមទាំងជំងឺលើសសម្ពាធឈាម)
   3. ជំងឺតម្រងនោមរ៉ាំរ៉ៃ
   4. ជំងឺថ្លើមរ៉ាំរ៉ៃ (ជំងឺក្រិនថ្លើម ជាដើម)
   5. ជំងឺទឹកនោមផ្អែមដែលព្យាបាលដោយការប្រើថ្នាំអាំងស៊ុយលីន ឬឱសថ ឬជំងឺទឹកនោមផ្អែមពាក់ព័ន្ធនឹងជំងឺផ្សេងៗ
   6. ជំងឺឈាម (មិនរាប់បញ្ចូលជំងឺស្លេកស្លាំងដោយសារខ្វះជាតិដែក)
   7. ជំងឺដែលធ្វើឱ្យខូចដំណើរការប្រព័ន្ធភាពស៊ាំ (រួមបញ្ចូលទាំងដុំសាច់មហារីកដែលកំពុងស្ថិតក្រោមការព្យាបាល)
   8. ការទទួលបានការព្យាបាល ដែលធ្វើឱ្យធ្លាក់ចុះនូវប្រព័ន្ធភាពស៊ាំ
   9. ជំងឺប្រព័ន្ធប្រសាទ និងសរសៃប្រសាទនិងសាច់ដុំ ពាក់ព័ន្ធនឹងភាពមិនប្រក្រតីនៃប្រព័ន្ធភាពស៊ាំ
   10. ដំណើរការរាងកាយធ្លាក់ចុះ ដោយសារតែជំងឺប្រព័ន្ធប្រសាទ និងសរសៃប្រសាទនិងសាច់ដុំ (រួមបញ្ចូលទាំងជំងឺផ្លូវដង្ហើម)
   11. ភាពមិនប្រក្រតីក្រូម៉ូសូម
   12. អសមត្ថភាពផ្លូវស្មារតី និងរូបរាងកាយធ្ងន់ធ្ងរ (អសមត្ថភាពរូបរាងកាយធ្ងន់ធ្ងរ និងអសមត្ថភាពបញ្ញាស្មារតីធ្ងន់ធ្ងរ)
   13. ជំងឺស្ទះដង្ហើមពេលគេង
   14. ជំងឺផ្លូវចិត្តធ្ងន់ធ្ងរ (សម្រាកព្យាបាលជំងឺផ្លូវចិត្តនៅមន្ទីរពេទ្យ មានលិខិតបញ្ជាក់អំពីបញ្ហាពិការភាពផ្លូវចិត្ត ឬលិខិតបញ្ជាក់អំពីការស្តារនីតិសម្បទា ឬស្ថិតក្នុងប្រភេទ ការថែទាំវេជ្ជសាស្ត្រគាំទ្រខ្លួនឯង "ធ្ងន់ធ្ងរ និងជាប់ជាប្រចាំ" (ការថែទាំនៅក្នុងមន្ទីរពេទ្យចិត្តសាស្ត្រ)
2. អ្នកធាត់ដែលត្រូវតាមលក្ខណៈវិនិច្ឆ័យ (BMI 30ឡើងទៅ)
   BMI = ទម្ងន់រាងកាយ (kg) ÷ កម្ពស់ (m) ÷ កម្ពស់ (m)
   *ការណែនាំសម្រាប់ BMI នៃ 30៖ កម្ពស់ 170cm និងទម្ងន់ 87kg  កម្ពស់ 160cm និងទម្ងន់ 77kg

ការចាក់វ៉ាក់សាំងបុគ្គលិកបម្រើការងារនៅក្នុងមណ្ឌលចាស់ជរានឹងត្រូវចាប់ផ្តើមឡើងក្នុងពេលជាមួយគ្នា។

## ◎ ការចាក់វ៉ាក់សាំងនៅកន្លែងផ្សេង ក្រៅពីកន្លែងដែលមានសរសេរនៅក្នុងប័ណ្ណស្នាក់នៅដែលបានចុះបញ្ជី (ទីតាំងលំនៅដ្ឋាន)

- ប្រសិនបើអ្នកកំពុងទទួលវ៉ាក់សាំងនៅមន្ទីរពេទ្យ ឬមូលដ្ឋានសុខាភិបាល ដែលអ្នកកំពុងស្នាក់នៅ ឬចូលសម្រាកព្យាបាល → សូមធ្វើការពិគ្រោះយោបល់ជាមួយនឹងមន្ទីរពេទ្យ ឬមូលដ្ឋានសុខាភិបាលនោះ។
- ប្រសិនបើអ្នកកំពុងទទួលវ៉ាក់សាំងនៅមន្ទីរពេទ្យ ដែលអ្នកកំពុងព្យាបាលជំងឺប្រចាំកាយ → សូមធ្វើការពិគ្រោះយោបល់ជាមួយនឹងមន្ទីរពេទ្យនោះ។
- ប្រសិនបើលំនៅដ្ឋានរបស់អ្នក ខុសពីអាសយដ្ឋានរបស់អ្នក → អ្នកអាចទទួលវ៉ាក់សាំងនៅក្នុងតំបន់ដែលអ្នកកំពុងរស់នៅជាក់ស្តែង។
- សូមពិនិត្យមើលការណែនាំអំពីវ៉ាក់សាំងសម្រាប់មេរោគកូវីដ ឬទាក់ទងមកកាន់ការិយាល័យពិគ្រោះយោបល់របស់សាលាក្រុងដែលអ្នកកំពុងរស់នៅ។

## ◎ ត្រូវស្នើសុំការយល់ព្រមជាមុនសិន មុននឹងធ្វើការចាក់វ៉ាក់សាំង

ប្រសិនបើអ្នកកំពុងស្ថិតនៅក្នុងការព្យាបាលជំងឺ ឬមានការបារម្ភអំពីស្ថានភាពសុខភាពរបស់អ្នក សូមពិគ្រោះយោបល់ជាមួយនឹងវេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់អ្នក មុនពេលសម្រេចចិត្តទទួលយកវ៉ាក់សាំងនោះ។

| | |
|---|---|
| សម្រាប់ព័ត៌មានបន្ថែមអំពីប្រសិទ្ធភាព និងសុវត្ថិភាពរបស់វ៉ាក់សាំងសម្រាប់មេរោគកូវីដ សូមចូលទៅកាន់ទំព័រវ៉ាក់សាំងសម្រាប់មេរោគកូវីដនៅលើវេបសាយត៍របស់នាយករដ្ឋមន្ត្រីជប៉ុន និងខុទ្ទកាល័យរបស់គាត់។ វ៉ាក់សាំងមេរោគកូវីដនាយករដ្ឋមន្ត្រីជប៉ុន និងខុទ្ទកាល័យ ស្វែងរក | |
| ប្រសិនបើអ្នកមិនអាចបើកវេបសាយត៍នេះបានទេ សូមទាក់ទងទៅកាន់សាលាក្រុងក្នុងមូលដ្ឋានរបស់អ្នក។ | |

ព័ត៌មានទំនាក់ទំនងសម្រាប់ការសួរសំណួរ